Everett
សាលារៀនសាធារណៈ

Priya Tahiliani
ប្រធាននាយកសាលា
121 Vine Street, Everett, MA

12 មីនា 2020

សហគមន៍សាលារៀនក្រុង Everett ជាទីគោរព

មកទល់ពេលនេះ លោកអ្នកគួរតែទទួលបានព័ត៌មានសំខាន់ៗពីក្រុង Everett ក្នុងការសម្រេចបិទទ្វារសាលារៀនចាប់ពីថ្ងៃស្អែកនេះ ដែលត្រូវនឹងថ្ងៃសុក្រ ទី13 មីនា 2020 ហើយសិស្សានុសិស្សនឹងចូលរៀនវិញនៅថ្ងៃចន្ទ ទី 27 មេសា 2020។

ខ្ញុំយល់ថាការសម្រេចបិទទ្វារសាលារៀននឹងបង្កការរំខាន ក៏ប៉ុន្តែយើងខ្ញុំជឿជាក់ថាការណ៍នេះគឺជាវិធីដ៏ប្រសើរបំផុតមួយក្នុងកាត់បន្ថយការឆ្លងរាលដាលនៃជំងឺ Coronavirus។ EPS នឹងផ្តល់ជូនកញ្ចប់អាហារពីឡប់ប៊ីនៃសាលា Everett High School ចាប់ពីម៉ោង 11 ព្រឹកដល់ម៉ោង 1 រសៀល ពីថ្ងៃចន្ទដល់សុក្រ។ អាហារថ្ងៃត្រង់ទាំងនេះមានផ្តល់ជូនចាប់ពីថ្ងៃចន្ទទី 16 មីនា រហូតដល់ថ្ងៃសុក្រ ទី 17 មេសា លើកលែងតែថ្ងៃបុណ្យ Good Friday នៅថ្ងៃទី 10 មេសា។ ដើម្បីទទួលបានអាហារទាំងនេះ សិស្សចាំបាច់ត្រូវចុះឈ្មោះនៅតាមសាលារៀនសាធារណៈក្រុង Everett ឬសាលារៀន Saint Anthony។

យើងមិនអាចគូសបញ្ជាក់ឲ្យបានសមល្មមដែលថាអាទិភាពរបស់យើងនៅ EPS គឺដើម្បីសុខភាពនិងសុខុមាលភាពនៃសិស្សានុសិស្សរបស់យើង ក្រុមគ្រួសារ បុគ្គលិក និងសហគមន៍សាលារៀនទាំងមូលឡើយ។ ពីព្រោះថាសុវត្ថិភាពសហគមន៍របស់យើងនៅតែជាការយកចិត្តទុកដាក់ជាសំខាន់របស់យើង យើងសង្ឃឹមថាលោកអ្នកនិងគ្រួសារនឹងមានសុវត្ថិភាពនិងមានសុខភាពល្អ។

ដោយក្តីគោរពរាប់អាន

Priya Tahiliani
ប្រធាននាយកសាលា

Everett
សាលារៀនសាធារណៈ

Priya Tahiliani
ប្រធាននាយកសាលា
121 Vine Street, Everett, MA

សារស្វ័យប្រវត្តិសម្រាប់គ្រួសារ